# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៣៦/១៨ ក.ប/សជណ.លប

ថ្ងៃ ព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១៨

## សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បេក្ខជនទាំងអស់ឱ្យបានជ្រាបថា **លទ្ធផលជាប់ជាស្ថាពរ និងជាប់បម្រុង នៃការប្រឡងជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌថ្មីកាលពីថ្ងៃសុក្រ ១០កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ នៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ នឹងបិទប្រកាសនៅទីស្តីការក្រសួង និងវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ នាថ្ងៃព្រហស្បតិ៍ ១រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ១៥:០០ នាទីរសៀល។**

ដោយឡែកដើម្បីឱ្យមានតម្លាភាពចំពោះបេក្ខជន ដែលបានប្រឡងជាប់ជាស្ថាពរនៅទីស្តីការក្រសួង (ថ្នាក់កណ្តាល) ចំនួន **០៤នាក់** ក្រសួងនឹងធ្វើការរៀបចំបែងចែកប៉ុស្តិ៍ និងជ្រើសរើសកន្លែងបម្រើការងាររបស់មន្ត្រីនីមួយៗ ដោយទុកឱកាសឱ្យអ្នកដែលមានចំណាត់ថ្នាក់ខ្ពស់និងថ្នាក់បន្តបន្ទាប់ មានសិទ្ធិជ្រើសរើសប៉ុស្តិ៍ (អង្គភាពដែលខ្លួនចង់ទៅបម្រើការងារ) រៀងៗខ្លួន។ ដូចនេះសូមបេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរទាំងអស់ (ទីស្តីការក្រសួង និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត) ត្រូវចូលរួមប្រជុំស្តាប់ការណែនាំ និងបំពេញឯកសារផ្សេងៗជាមួយនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក **នាថ្ងៃពុធ ៧រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ០៩:០០ នាទីព្រឹក នៅសាលប្រជុំ D ទីស្តីការក្រសួង។**

❖ **បញ្ជាក់៖ ចំពោះបេក្ខជនដែលអវត្តមាន ឬមិនបានចូលរួមតាមការអញ្ជើញនេះ ក្រសួងចាត់ទុកថាឯកភាពតាមការចាត់តាំងរបស់ក្រសួង ដោយមិនអាចតវ៉ាឬស្នើសុំផ្លាស់ប្តូរនៅពេលក្រោយបានឡើយ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម បេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រី**
**អនុរដ្ឋលេខាធិការ និងជា**
**អនុប្រធានគណៈកម្មការរៀបចំការប្រឡង**

**ទៀង ម៉ាក់តែល**

ព័ត៌មានបន្ថែមសូមទំនាក់ទំនង:

- លោក គួយ គៀន ០៧៧ ៥១៨ ៥១១
- លោក ងួន ឆេង ០១២ ៧៣៣ ៤១១
- លោកស្រី ឡាយ ម៉ារីណា ០៩៨ ៩៩០ ០៣៤